# គាថានមស្ការព្រះពុទ្ធជាបុរសអាជានេយ្យ

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
សព្វញ្ញូសិ មហាវីរ, លោកជេដ្ឋ នរាសភ ។

បពិត្រព្រះអង្គជាបុរសជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក
ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញុពុទ្ធ ។

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន បទុមកេសរវគ្គ អាសនសន្ថវិកត្ថេរស្សាបទាន បិដក ៧៤ ទំព័រ ១៩)*

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
ពហុជ្ជនំ តារយសិ, ទេសេន្តោ អមតំ បទំ ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ
ព្រះអង្គកាលសម្តែងនូវអមតបទ គឺព្រះនិព្វាន
ញុំាងជនដ៏ច្រើន ឲ្យឆ្លងវដ្តទុក្ខបាន ។

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថោមកវគ្គ ថោមកត្ថេរស្សាបទាន បិដក ៧៣ ទំព័រ ១៨៨)*

រូបេ សីលេ សមាធិម្ហិ, បញ្ញាយ ច អសាទិសោ;

វិមុត្តិយា អសមសមោ, ធម្មចក្កប្បវត្តនេ ។

*ព្រះអង្គមិនមានបុគ្គលស្មើ ក្នុងព្រះរូបផង*

*សីលផង សមាធិផង បញ្ញាផង*

*ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើ*

*ចំពោះវិមុត្តិធម៌ និងការញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំស រតនចង្កមនកណ្ឌ បិដកលេខ ៧៧ ទំព័រ ១៣)*

លាភាលាភេ ន សជ្ជន្តិ, សម្មាននវិមាននេ;

បថវីសទិសា ពុទ្ធា, តស្មា តេ ន វិរាធិយា ។

*ព្រះពុទ្ធទាំងឡាយមានចិត្តស្មើដោយផែនដី*

*មិនជាប់ជំពាក់ក្នុងលាភ និងអលាភ*

*ក្នុងការរាប់អាន ក្នុងការមើលងាយ*

*ហេតុនោះ*

*បុគ្គលមិនគប្បីឲ្យផ្តាំផ្តងនឹងព្រះពុទ្ធទាំងនោះឡើយ ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ពុទ្ធវគ្គ ឧបាលិត្ថេរអបទាន*

*បិដក ៧២ ទំព័រ១០៨)*

*ដោយសដវថ*